# តើនរណាជាទស្សនវិទូ?

*ដោយ*

*ប្រែង ពិសិដ្ឋ និង ម៉ិល វាសនា*
*មន្ត្រីវិទ្យាស្ថានវប្បធម៌និងវិចិត្រសិល្បៈនៃរាជបណ្ឌិត្យសភាកម្ពុជា*

បច្ចុប្បន្ននេះ យើងឃើញនៅក្នុងសង្គមកម្ពុជាមានប្រើបញ្ញត្តិ *វិទូ* ភ្ជាប់ជាមួយមុខវិជ្ជាជំនាញផ្សេងៗសម្រាប់ហៅបុគ្គល(ខ្មែរ)ជាអ្នកមានចំណេះជំនាញខ្ពង់ខ្ពស់លើមុខវិជ្ជាទាំងនោះ មានជាអាទិ៍ ប្រវិត្តិវិទូ សេដ្ឋវិទូ នរវិទូ បុរាណវិទូ ។ល។ ប៉ុន្តែហាក់មិនទាន់ឃើញមានការប្រើបញ្ញត្តិ *ទស្សនវិទូ* សម្រាប់ហៅបុគ្គលជាខ្មែរ ដែលបានសិក្សារៀនសូត្រខ្ពង់ខ្ពស់លើមុខជំនាញទស្សនវិជ្ជានៅឡើយ។ តើបញ្ញត្តិ *ទស្សនវិទូ* មានអត្ថន័យដូចម្តេច? តើនរណាជាទស្សនវិទូ?

អត្ថបទនេះមិនមែនជាការសិក្សាស៊ីជម្រៅអំពីបញ្ញត្តិ *ទស្សនវិទូ* ឬ ឈានទៅដល់ការកំណត់នូវលក្ខណៈសម្បត្តិជាក់លាក់របស់ទស្សនវិទូនោះឡើយ តែវាអាចជាសញ្ញាណសម្រាប់ការយល់ដឹងខ្លះប៉ុណ្ណោះ។

ខាងក្រោមនេះជាទស្សនៈមួយចំនួនអំពីបញ្ញត្តិ « ទស្សនវិទូ » ៖

- បញ្ញត្តិ *ទស្សនវិទូ* និង *ទស្សនវិជ្ជា* បង្កើតឡើងដោយអ្នកគិតជនជាតិក្រិចឈ្មោះ ពីតាហ្គ័រ (Pythagoras) ។ ពាក្យ *ទស្សនវិទូ* បានជំនួសពាក្យ *អ្នកមានប្រាជ្ញា* (sophist) ដែលគេបានប្រើដើម្បីពិពណ៌នាអំពី *អ្នកឆ្លាតវៃ* ជាគ្រូវោហាសាស្ត្រ ដែលជាមនុស្សសំខាន់នៅបុរីប្រជាធិបតេយ្យអាតែន។

- តាមន័យដើម នរណាម្នាក់ជាទស្សនវិទូ លុះត្រាតែគាត់សម្រេចចិត្តរស់នៅដោយការបូជាជីវិតដើម្បីគុណធម៌និងការគិតពិចារណាពីវត្ថុដែលមិនមានទីបញ្ចប់។ ប៉ុន្តែការប្រើពាក្យនេះមានការប្រែប្រួល ពិសេសនៅសម័យបុនភពនិងការលេចពន្លឺជាថ្មី ( Renaissance and Enlightenment )។ នៅសតវត្សទី២០ ការប្រើពាក្យនេះបានធ្វើឱ្យមានការភាន់ច្រឡំ។

- អ្នកសិក្សាភាគច្រើនប្រើពាក្យ *ទស្សនវិទូ* ក្នុងន័យកិត្តិយស គឺមិនមែនសម្រាប់ពិពណ៌ចំពោះមនុស្សដែលធ្វើការងារលើបញ្ហាផ្សេងៗឡើយ។ ប៉ុន្តែ សម្រាប់ទស្សនវិទូ គឺមិនបានចាត់ទុកពាក្យ *ទស្សនវិទូ* ក្នុងន័យកិត្តិយសឡើយ។

- គេអាចកំណត់នរណាម្នាក់ជាទស្សនវិទូតាមរយៈប្រធានបទដែលគាត់បានសរសេរ ពោលគឺ បើប្រធានបទទាំងឡាយរបស់គាត់ស្ថិតនៅក្នុងបញ្ហាទស្សនវិជ្ជា នោះគាត់គឺជាទស្សនវិទូ។ តែបើប្រធានបទរបស់គាត់មិនស្ថិតនៅក្នុងរង្វង់បញ្ហាទស្សនវិជ្ជាទេ នោះគាត់មិនមែនជាទស្សនវិទូទេ។

យើងឃើញថា រហូតមកដល់បច្ចុប្បន្ននេះ ហាក់មិនមានការឯកភាពគ្នាអំពីកិច្ចការដែលទស្សនវិទូត្រូវធ្វើ និងអំពីការកំណត់ថា ខ្លឹមសារអត្ថបទបែបណាជាអត្ថបទទស្សនវិជ្ជា សំណួរបែបណាជាសំណួរបែបទស្សនវិជ្ជា និងវិធីបែបណាជាវិធីទស្សនវិជ្ជាឡើយ។ (ការសិក្សាទស្សនវិជ្ជាមិនមានវិធីជាគំរូសម្រាប់ឱ្យអ្នកសិក្សាអនុវត្តតាមឡើយ។)

- អ្នកខ្លះផ្តល់និយមន័យថា ទស្សនវិទូគឺជាអ្នកបង្កើតទ្រឹស្តីទូទៅដ៏ល្អអំពីមុខវិជ្ជាមួយ ដូចជាការវិភាគខាងវប្បធម៌ ប្រវត្តិសាស្ត្រ អក្សរសាស្ត្រ ឬ នយោបាយ ជាដើម។

- ទស្សនៈខ្លះលើកឡើងថា ទស្សនវិទូគឺផ្តោតជាសំខាន់លើការទាញបាននូវទស្សនៈផ្សេងៗចេញឆ្ងាយពីបរិបទ ហើយវិភាគវាពីទស្សនវិស័យជាវត្ថុវិស័យ ដោយមិនផ្តោតជាចាំបាច់លើការអនុវត្តទស្សនៈនោះទេ។

- ទស្សនវិទូមិនមែនគ្រាន់តែជាអ្នកគិតដ៏អស្ចារ្យនោះទេ តែគឺជាមនុស្សស្មោះត្រង់មានសច្ចភាពផងដែរ។ ហេតុនេះ អ្នកប្រាជ្ញមិនសុទ្ធតែអាចជាទស្សនវិទូឡើយ ព្រោះអ្នកប្រាជ្ញអាចមិនមែនជាមនុស្សស្មោះត្រង់ មានសច្ចភាព។

- ទស្សនវិទូ គឺជាបុគ្គលដែលបានបង្កើតឡើងដោយចេតនានូវស្នាដៃមានសារសំខាន់អំពីទស្សនវិជ្ជាដោយមធ្យោបាយផ្សេងៗ ដោយមិនប្រឌិត និងមិនមែនជាជីវប្រវត្តិ។ *ដោយចេតនា* មានន័យថា មិនមែនចៃដន្យ ពោលគឺបុគ្គលដឹងថាខ្លួនកំពុងធ្វើទស្សនវិជ្ជា។ *ស្នាដៃមានសារៈសំខាន់* គឺស្នាដៃនិយាយអំពី តក្កវិជ្ជា សីលវិជ្ជា បរិមត្ថវិជ្ជា ទ្រឹស្តីពុទ្ធិ និងទស្សនវិជ្ជាសាសនា ជាដើម។ *តាមមធ្យោបាយផ្សេងៗ* មានន័យថា អាចតាមរយៈសៀវភៅ ការថ្លែង ឬ សកម្មភាពផ្សេងៗ ជាអាទិ សូក្រាត មិនបានសរសេរសៀវភៅទេ តែជាការថ្លែង , Wittgenstein មានសៀវភៅសំខាន់តែ១ ឬ ២ ប៉ុណ្ណោះ តែមានអត្ថបទនិងមេរៀនច្រើន , Kierkegaard មានការនិពន្ធច្រើន។ *មិនប្រឌិត* មានន័យថា មិនមែនជាលក្ខណៈអក្សរសិល្ប៍ តែអាចជាស្នាដៃមានលក្ខណៈទ្រឹស្តី។ *មិនមែនជីវប្រវត្តិ* មានន័យថា មិនសរសេរទស្សនវិជ្ជាក្នុងកំណត់ហេតុប្រចាំថ្ងៃ។

យើងសង្កេតឃើញថា ហាក់មិនទាន់មានការកំណត់ឱ្យបានច្បាស់លាស់ពីលក្ខណៈសម្បត្តិជាទស្សនវិទូឡើយ។ ជាក់ស្តែង លោក Kierkegaard បានស្នើយ៉ាងទទូចឱ្យហៅលោកថា *កវី* ឯ Nietzsche ទទូចថា លោកជាចិត្តវិទូ តែគេបានចាត់ទុកលោកទាំងពីរជា ទស្សនវិទូ។

មានការបែងចែកខុសគ្នារវាង *អ្នកទ្រឹស្តីនយោបាយ* (Political theorist) និង *ទស្សនវិទូនយោបាយ* (Political philosopher) ដោយអ្នកខ្លះជាអ្នកទ្រឹស្តីនយោបាយ មិនមែនជាទស្សនវិទូនយោបាយឡើយ។ អ្នកទ្រឹស្តីនយោបាយបានរួមបញ្ចូលនូវព្រឹត្តិការណ៍និងប្រវត្តិសាស្ត្រនៅក្នុងការវិភាគគំនិតរបស់ខ្លួន ខណៈដែលទស្សនវិទូនយោបាយមិនធ្វើដូច្នេះឡើយ តែគឺសិក្សាស្រាវជ្រាវរកក្បួនគំរូនយោបាយ ពោលគឺ *ទ្រឹស្តីមនោគតិ* (ideal theory) ។ ជាងនេះទៀត អ្នកសិក្សាក្នុងដេប៉ាតឺម៉ង់ទស្សនវិជ្ជាអាចធ្វើការក្នុងដេប៉ាតឺម៉ង់នយោបាយបាន តែអ្នកសិក្សាក្នុងដេប៉ាតឺម៉ង់នយោបាយមិនអាចធ្វើការក្នុងដេប៉ាតឺម៉ង់ទស្សនវិជ្ជាបានទេ។

ជារួម យើងសង្កេតឃើញមានទស្សនៈពីរទាក់ទងនឹងការកំណត់ថា តើនរណាម្នាក់ជាទស្សនវិទូ។ ទី១ ការកំណត់ក្នុងន័យកិច្ចការទស្សនវិជ្ជាដែលគេបានធ្វើ និង ទី២ កំណត់ក្នុងន័យកិត្តិយស។ បើគេកំណត់ទស្សនវិទូក្នុងន័យធ្វើកិច្ចការទស្សនវិជ្ជា គឺវាមិនមែនជាការស្មុគស្មាញពេកទេ ព្រោះវានឹងផ្អែកលើថា ជាអ្នកសិក្សាទស្សនវិជ្ជា ជាបណ្ឌិតទស្សនវិជ្ជា ជាអ្នកបង្រៀនទស្សនវិជ្ជា សរសេរទស្សនវិជ្ជា គិតវិភាគពិចារណាតាមបែបទស្សនវិជ្ជា។ ប៉ុន្តែ បើក្នុងន័យកិត្តិយសវិញ គឺវាមានការលំបាកនិងមានភាពមិនច្បាស់លាស់ ព្រោះមិនមានការកម្រិតឱ្យបានច្បាស់លាស់ និងទាមទារនូវតម្លៃខ្ពស់ដើម្បីទទួលងារជាទស្សនវិទូ។ ប្រហែលជាយើងកំពុងស្ថិតនៅក្នុងទស្សនៈទី២ ទើបយើងហាក់ស្ទាក់ស្ទើរក្នុងការហៅបុគ្គលខ្មែរ ដែលបានសិក្សាខ្ពង់ខ្ពស់និងបង្ហាត់បង្រៀនមុខវិជ្ជាទស្សនវិជ្ជាជាទស្សនវិទូដោយងាយៗ ខណៈដែលមុខវិជ្ជាផ្សេងៗហាក់ងាយជាងនេះ។